

# ជំនួយសាធារណៈក្នុងគ្រាជំងឺរាលដាលសម្រាប់អ្នកស្នាក់នៅក្នុងខោនធី Alameda

## កម្មវិធី Supplemental Security Income/State Supplementary Payment (SSI/SSP)

**លក្ខណៈសម្បត្តិ៖** កម្មវិធី SSI ជាកម្មវិធីរដ្ឋសហព័ន្ធសម្រាប់បុគ្គលមានប្រាក់ចំណូលទាប អាយុ 65 និង ច្រើនជាងនេះ ឬជាជនពិការភ្នែក ឬជនពិការ។ កម្មវិធី SSP ជាកម្មវិធីរដ្ឋបន្ថែមលើកម្មវិធី SSI។ កម្មវិធី SSI និង SSP ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលសន្តិសុខសង្គម (Social Security Administration (SSA))។

**សេចក្តីលម្អិត៖** ត្រូវតែបំពេញតាមកម្រិតប្រាក់ចំណូល និងទ្រព្យ។ អត្រាជំនួយក្នុងឆ្នាំ 2021 មានចំនួន $955 សម្រាប់បុគ្គល និង $1,598 សម្រាប់ប្តីប្រពន្ធ។

**សម្រាប់ព័ត៌មានបន្ថែម៖** https://www.ssa.gov/benefits/ssi/

## កម្មវិធី Cash Assistance Program for Immigrants (CAPI)

**លក្ខណៈសម្បត្តិ៖** កម្មវិធី CAPI ជាកម្មវិធីមូលនិធិរដ្ឋ 100% សម្រាប់បុគ្គលទាំងឡាយដែលគ្មានលក្ខណៈសម្បត្តិសម្រាប់កម្មវិធី SSI /SSP ដោយសារតែឋានៈអន្តោប្រវេសន៍របស់ខ្លួន។ កម្មវិធី CAPI ត្រូវបានគ្រប់គ្រងតាមរយៈ ACSSA។

**សេចក្តីលម្អិត៖** ប្រាក់ពីកម្មវិធី CAPI មានចំនួនស្មើនឹងចំនួនប្រាក់ដែលផ្តល់ជូនតាមរយៈកម្មវិធីSSI/SSP។

**សម្រាប់ព័ត៌មានបន្ថែម៖**
https://www.alamedacountysocialservices.org/our-services/Immigrants-and-Refugees/CAPI#overview

## កម្មវិធី CalFresh & Enhanced CalFresh

**លក្ខណៈសម្បត្តិ៖** ត្រូវតែមានលក្ខណៈសម្បត្តិសម្រាប់កម្មវិធី CalFresh។

**សេចក្តីលម្អិត៖** គ្រួសារទាំងអស់ទទួលបាននូវប្រាក់ជំនួយអតិបរមាប្រចាំខែពីកម្មវិធី CalFresh ផ្អែកលើទំហំគ្រួសាររបស់ខ្លួន ដោយមិនគិតពីចំណូលនិងចំណាយទេ។ ជំនួយមានជូនតាមរយៈដំណើរការពិនិត្យឡើងវិញ និងលក្ខណៈសម្បត្តិរបស់ខោនធី/ACSSA។

**សម្រាប់ព័ត៌មានបន្ថែម៖**
https://www.alamedacountysocialservices.org/our-services/Health-and-Food/CalFresh/index

## Pandemic-EBT (P-EBT) 3.0 និង Summer P-EBT

**លក្ខណៈសម្បត្តិ៖** កុមារអាយុ 0-6 ឆ្នាំ ក្នុងគ្រួសារដែលទទួលបានជំនួយអាហារពីកម្មវិធី CalFresh ក្នុងចន្លោះខែសីហា ឆ្នាំ 2021- 2022។ កូនសិស្សដែលមានលក្ខណៈសម្បត្តិទទួលបានអាហារឥតគិតថ្លៃ ឬបញ្ចុះតម្លៃ ដែលបានចុះឈ្មោះក្នុងការសិក្សាឯករាជ្យ ពេលមានវិបត្តិជំងឺកូវីដ ក្នុងឆ្នាំសិក្សា 2021-2022។

**សេចក្តីលម្អិត៖** គ្មានការដាក់ពាក្យសុំ P-EBT 3.0 ទេ។ កាត P-EBT នឹងត្រូវផ្ញើជូនតាមប្រៃសណីយ៍ដោយស្វ័យប្រវត្តិ ចាប់ពីខែតុលា ឆ្នាំ 2022។ មានខ្សែ P-EBT Helpline លេខ (877)328-9677 ថ្ងៃចន្ទ - ថ្ងៃសុក្រ ម៉ោង 6am ដល់ 8pm។

**សម្រាប់ព័ត៌មានបន្ថែម៖** https://capandemic-ebt.org/

## កម្មវិធី Women, Infant & Children Program (WIC)

**លក្ខណៈសម្បត្តិ៖** កម្មវិធី WIC មានជូនស្ត្រីផ្ទៃពោះ ឬបំបៅកូន មានទារក និងកូនតូចៗ ប្រសិនបើអ្នកដាក់ពាក្យសុំមានប្រាក់ចំណូលប្រចាំឆ្នាំនៅអត្រា ឬទាបជាងអត្រា 185% នៃខ្សែបន្ទាត់ភាពក្រីក្ររបស់រដ្ឋសហព័ន្ធ។ (បច្ចុប្បន្ន $48,470 សម្រាប់គ្រួសារសមាជិកបួននាក់)។ ជនណាទើបបាត់បង់ការងារថ្មីៗនេះ ឬមិនអាចធ្វើការងារបានដោយសារវិបត្តិជំងឺកូវីដ-19 ប្រហែលអាចមានលក្ខណៈសម្បត្តិ។

**សេចក្តីលម្អិត៖** កម្មវិធីសុខភាព និងអាហារូបត្ថម្ភសម្រាប់ស្ត្រី និងកុមារអាយុ 5 ឆ្នាំ ដាក់ពាក្យសុំតាមរយៈក្រសួងសុខាភិបាលសាធារណៈ។

**សម្រាប់ព័ត៌មានបន្ថែម៖** https://acphd.org/wic/

## Local Emergency Food Distribution

**លក្ខណៈសម្បត្តិ៖** បុគ្គល ឬគ្រួសារជួបប្រទះអសន្តិសុខស្បៀង ឬត្រូវការសេវាកម្មដឹកជញ្ជូនស្បៀង ឬអាហារក្នុងគ្រាអាសន្ន។

**សេចក្តីលម្អិត៖** ហៅទូរស័ព្ទមកលេខ 2-1-1 ឬប្រើផែនទីបង្ហាញទីកន្លែងចែកស្បៀង ធ្វើតេស្ត និងសេវាកម្មផ្សេងៗ ពេលមានវិបត្តិជំងឺកូវីដរបស់ខោនធី Alameda ដើម្បីស្វែងរកកន្លែងចែកស្បៀង ដែលនៅក្បែរអ្នក។

**សម្រាប់ព័ត៌មានបន្ថែម៖** https://www.acgov.org/maps/food-services.htm

## កម្មវិធី Season of Sharing Program (SOS)

**លក្ខណៈសម្បត្តិ៖** អ្នកស្នាក់នៅក្នុងខោនធី Alameda ដែលមានកូនក្នុងបន្ទុក ឬក៏ជាជនពិការ អាយុ 55 ឆ្នាំ ឬលើសនេះ ជាអតីតយុវជននៅមណ្ឌលថែទាំ ជាអតីតយុទ្ធជន ជាអ្នករស់រានជីវិតពីអំពើហិង្សារបស់ដៃគូ និងបទល្មើសហិង្សាផ្សេងៗ និងជាអ្នកមានផ្ទៃពោះ។

**សេចក្តីលម្អិត៖** ជំនួយមួយលើកជូនបុគ្គលដែលជួបប្រទះវិបត្តិផ្ទះសម្បែង ដែលអាចដោះស្រាយបានតាមរយៈជំនួយមួយលើក។ សូមហៅមកខ្សែទូរស័ព្ទពិនិត្យជាមុនលេខ 510-272-3700។

**សម្រាប់ព័ត៍មានបន្ថែម៖**
[https://www.alamedacountysocialservices.org/our-services/Shelter-and-Housing/Other-Support/season-of-sharing](https://www.alamedacountysocialservices.org/our-services/Shelter-and-Housing/Other-Support/season-of-sharing)

## កម្មវិធី Housing & Emergency Lodging Program (HELP)

**លក្ខណៈសម្បត្តិ៖** បុគ្គលពេញវ័យជាមេគ្រួសារទោល កំពុងរស់នៅក្នុងខោនធី Alameda ដែលមិនបំពេញបាននូវលក្ខណៈសម្បត្តិសម្រាប់កម្មវិធី SOS ហើយគ្មានផ្ទះសម្បែង ឬមានហានិភ័យគ្មានផ្ទះសម្បែង និងបន្តមានប្រាក់ចំណូល។

**សេចក្តីលម្អិត៖** កម្មវិធី HELP នឹងផ្តល់ជំនួយហិរញ្ញវត្ថុមួយលើកផ្អែកលើវិបត្តិ សម្រាប់តម្រូវការផ្ទះសម្បែងសំខាន់ចាំបាច់។ ដើម្បីដាក់ពាក្យសុំ សូមហៅទូរស័ព្ទមកលេខ 510- 259-2200 ឬអ៊ីម៉ែលមក **HoEmLodgP@acgov.org.**។

**សម្រាប់ព័ត៍មានបន្ថែម៖**
[https://www.alamedacountysocialservices.org/our-services/Shelter-and-Housing/Other-Support/HELP](https://www.alamedacountysocialservices.org/our-services/Shelter-and-Housing/Other-Support/HELP)

## ប្រភពធនធានថែទាំកុមារ និងទីភ្នាក់ងារណែនាំបញ្ជូន

**សេចក្តីលម្អិតពីការបញ្ជូន៖** គ្រួសារ ដែលរស់នៅក្នុងខោនធី Alameda, Albany, Berkeley, Emeryville, Oakland, ឬ Piedmont អាចទូរស័ព្ទមកលេខ 510-658-0381 ឬអ៊ីម៉ែលមក **referrals@bananasbunch.org** គ្រួសារ ដែលរស់នៅ Castro Valley, Fremont, Hayward, Newark, San Leandro, San Lorenzo, ឬ Union City អាចទូរស័ព្ទមកលេខ 510-244-0506 ឬអ៊ីម៉ែលមក **info@4c-alameda.org.** គ្រួសារ ដែលរស់នៅ Dublin, Livermore, Pleasanton, ឬ Sunol អាចទូរស័ព្ទមកលេខ 925-417-8733 ឬអ៊ីម៉ែលមក **hello@behively.org.**។

# ឥណទានពន្ធរដ្ឋសហព័ន្ធ

### ឥណទានពន្ធលើប្រាក់ចំណូល (Earned Income Tax Credit (IEITC)

**លក្ខណ:សម្បត្តិ៖** រកបានប្រាក់ចំណូលទាបជាងកម្រិតកំណត់ដែលផ្អែកលើទំហំគ្រួសារ និងជាពលរដ្ឋអាមេរិក ឬជាជនបរទេសមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍។
**សេចក្តីលម្អិត៖** សម្រាប់ឆ្នាំពន្ធ 2021 តែប៉ុណ្ណោះ ឥណទានអតិបរមា គឺ $1,052 សម្រាប់បុគ្គល - ឥណទានអតិបរមាឆ្នាំមុន គឺ $543។ ប្តីប្រពន្ធមានកូន 3 ឬច្រើនជាងនេះ អាចទទួលបានមកវិញនូវប្រាក់ច្រើនចំនួន $6,728។
**សម្រាប់ព័ត៌មានបន្ថែម៖** https://www.irs.gov/credits-deductions/individuals/earned-income-tax-credit-eitc

### ឥណទានពនកុមារជាមុន Advance Child Tax Credit (CTC)

**លក្ខណ:សម្បត្តិ៖** បានដាក់លិខិតប្រកាសពន្ធឆ្នាំ 2019 ឬ 2020 ឬបញ្ចូលព័ត៌មានក្នុងពាក្យសុំ IRS ក្នុងឋាន:មិនមែនជាអ្នកដាក់លិខិតប្រកាសពន្ធ ហើយមានកូនក្នុងបន្ទុកអាយុក្រោម 18 ឆ្នាំ។
**សេចក្តីលម្អិត៖** សម្រាប់ឆ្នាំពន្ធ 2021 តែប៉ុណ្ណោះ។ ឥណទានប្រចាំឆ្នាំចំនួន $3,600 សម្រាប់កុមារអាយុក្រោម 6 ឆ្នាំ; ឥណទានប្រចាំឆ្នាំចំនួន $3,000 សម្រាប់កុមារអាយុ 6-17 ឆ្នាំ។ មានប្រាក់ប្រចាំខែសម្រាប់តម្លៃឥណទានពាក់កណ្តាល។ ផ្ទៀងផ្ទាត់ប្រាក់បង់មុនក្នុងលិខិតប្រកាសពន្ធឆ្នាំ 2021។
**សម្រាប់ព័ត៌មានបន្ថែម៖** https://www.irs.gov/credits-deductions/advance-child-tax-credit-payments-in-2021

### ឥណទានពន្ធលើការថែទាំកុមារ និង អ្នកក្នុងបន្ទុក

**លក្ខណ:សម្បត្តិ៖** អ្នកប្រកាសពន្ធ (មានរៀងរាល់ឆ្នាំពន្ធនីមួយៗ) បានបង់ប្រាក់ឲ្យជនម្នាក់ ឲ្យមើលថែទាំកុមារ ឬអ្នកក្នុងបន្ទុក ក្នុងអំឡុងពេលកំពុងធ្វើការ ឬស្វែងរកការងារធ្វើ។
**សេចក្តីលម្អិត៖** សម្រាប់ឆ្នាំពន្ធ 2021 ឥណទានអតិបរមាមានចំនួន $4,000 សម្រាប់កុមារម្នាក់ និង $8,000 សម្រាប់កុមារពីរនាក់ ឬច្រើន។
**សម្រាប់ព័ត៌មានបន្ថែម៖** https://www.irs.gov/forms-pubs/about-publication-503

# ឥណទានពន្ធរដ្ឋ California

### ឥណទានពន្ធលើប្រាក់ចំណូលរដ្ឋ California (California Earned Income Tax Credit (CalEITC)

**លក្ខណ:សម្បត្តិ៖** អ្នកពេញវ័យ ឬបុគ្គល ដែលកូនមានលក្ខណ:សម្បត្តិដែលមាន SSN ឬ ITIN មានសុពលភាព បានរកចំណូល ដាក់ប្រកាសពន្ធ និងមានចំណូលផ្ទៀងផ្ទាត់រួចចំនួន $30,000 ឬតិចជាងនេះប្រហែលអាចមានលក្ខណ:សម្បត្តិ។
**សេចក្តីលម្អិត៖** CalEITC គឺជាឥណទានពន្ធដែលអាចបង្វិលឲ្យវិញដើម្បីជួយបុគ្គល និងគ្រួសារចំណូលទាប និងមធ្យម។ ឥណទានអតិបរមាសម្រាប់បុគ្គលមានចំនួន $255 ហើយប្តីប្រពន្ធ មានកូនបី ឬច្រើននាក់អាចទទួលបានចំនួន $3,160។
**សម្រាប់ព័ត៌មានបន្ថែម៖** https://www.ftb.ca.gov/about-ftb/newsroom/caleitc/index.html

### ឥណទានពន្ធកុមារតូចៗ (Young Child Tax Credit (YCTC)

**លក្ខណ:សម្បត្តិ៖** ឪពុកម្តាយដែលកំពុងធ្វើការ មានចំណូលទាប និងមធ្យម មានកូនអាយុក្រោម 6 ឆ្នាំ ដែលដាក់លិខិតប្រកាសពន្ធ។ ជនទាំងឡាយ ដែលមានលក្ខណ:សម្បត្តិសម្រាប់ CalEITC ប្រហែលអាចមានលក្ខណ:សម្បត្តិសម្រាប់ YCTC។
**សេចក្តីលម្អិត៖** YCTC គឺជាឥណទានពន្ធដែលបង្វិលឲ្យវិញ ដើម្បីជួយគ្រួសារចំណូលទាប និងមធ្យម ដែលមានកូនតូចៗ។ ជំនួយអាចផ្តល់ជូនដល់ចំនួន $1,000 សម្រាប់អ្នកដាក់លិខិតប្រកាសពន្ធម្នាក់។
**សម្រាប់ព័ត៌មានបន្ថែម៖**
https://www.ftb.ca.gov/file/personal/credits/california-earned-income-tax-credit.html

# ប្រាក់ដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចរបស់រដ្ឋសហព័ន្ធ (Federal Economic Impact Payments (EIP)) ហៅថា “មូលប្បទានដោះស្រាយ”

## ប្រាក់ដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច ឆ្នាំ 2020

**លក្ខណ:សម្បត្តិ៖** បានដាក់លិខិតប្រកាសពន្ធឆ្នាំ 2019 ឬ 2020 ឬបានបញ្ចូលព័ត៌មានក្នុងពាក្យសុំ IRS ក្នុងឋានៈមិនមែនជាអ្នកដាក់លិខិតប្រកាសពន្ធ ចំណូលទាបជាងកម្រិតកំណត់ផ្អែកលើទំហំគ្រួសារ។

**សេចក្តីលម្អិត៖** ប្រាក់លើកទីមួយរហូតដល់ចំនួន $1,200 ក្នុងខែមេសា ឆ្នាំ 2020 និងប្រាក់លើកទីពីរចំនួន $600 ក្នុងខែធ្នូ ឆ្នាំ 2020។ ប្រាក់ភាគច្រើនបានចាត់ចែងរួចហើយ។ ដាក់ពាក្យទាមទារឥណទានពន្ធលើលិខិតប្រកាសពន្ធរដ្ឋសហព័ន្ធឆ្នាំ 2020 ឬ 2021 ប្រសិនបើមិនបានទទួលប្រាក់ដោះស្រាយ ឬបានទទួលតិចជាងចំនួនកំណត់។

**សម្រាប់ព័ត៌មានបន្ថែម៖**

https://www.irs.gov/newsroom/recovery-rebate-credit`

## ប្រាក់ដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច ឆ្នាំ 2021

**លក្ខណ:សម្បត្តិ៖** បានដាក់លិខិតប្រកាសពន្ធឆ្នាំ 2019 ឬ 2020 ឬបានបញ្ចូលព័ត៌មានទៅក្នុងពាក្យសុំ IRS ក្នុងឋានៈមិនមែនជាអ្នកដាក់លិខិតប្រកាសពន្ធ ចំណូលទាបជាងកម្រិតកំណត់ផ្អែកលើទំហំគ្រួសារ។ បុគ្គលពេញវ័យក្នុងបន្ទុកមានលក្ខណ:សម្បត្តិទទួលប្រាក់នៅជុំនេះប៉ុណ្ណោះ។

**សេចក្តីលម្អិត៖** ប្រាក់លើកទីបីរហូតដល់ចំនួន $1,400 ក្នុង និទាឃរដូវ ឆ្នាំ 2021 - បុគ្គលភាគច្រើនដែលមានលក្ខណ:សម្បត្តិ នឹងទទួលបានប្រាក់របស់ខ្លួនដោយស្វ័យប្រវត្តិ ហើយមិនចាំបាច់ធ្វើសកម្មភាពបន្ថែមទេ។ ដាក់ពាក្យទាមទារឥណទានពន្ធលើលិខិតប្រកាសពន្ធរដ្ឋសហព័ន្ធឆ្នាំ 2020 ឬ 2021 បើមិនបានទទួលប្រាក់ដោះស្រាយ ឬបានទទួលតិចជាងចំនួនកំណត់។

**សម្រាប់ព័ត៌មានបន្ថែម៖** https://www.irs.gov/coronavirus/third-economic-impact-payment

# ប្រាក់ដោះស្រាយរដ្ឋ California

## Golden State Stimulus I (GSS I)

**លក្ខណ:សម្បត្តិ៖** បានដាក់លិខិតប្រកាសពន្ធឆ្នាំ 2020 និងបានទទួលឥណទានពន្ធចំណូលរដ្ឋ California (California Earned IncomeTax Credit (CalEITC)) និងជាអ្នកប្រកាសពន្ធមានអត្តលេខអ្នកជាប់ពន្ធជាបុគ្គល (Individual Taxpayer Identification Number (ITIN)) ដែលមានចំណូលផ្ទៀងផ្ទាត់រួចចំនួន 75,000 ឬតិចជាងនេះ។

**សេចក្តីលម្អិត៖** GSS I ផ្តល់ប្រាក់មួយលើកចំនួន $600 ឬ $1,200 ជូនគ្រួសារ និងបុគ្គលចំណូលទាប ដែលមិនស្ថិតក្នុងកម្មវិធីប្រាក់ដោះស្រាយរបស់រដ្ឋសហព័ន្ធ ដោយសារឋានៈអន្តោប្រវេសន៍របស់ខ្លួន។ ថ្ងៃចុងក្រោយដើម្បីមានលក្ខណ:សម្បត្តិ បានកន្លងផុតហើយ សម្រាប់អ្នកដាក់លិខិតប្រកាសពន្ធ ក្រៅពីអ្នកមានលេខ ITINs កំពុងរង់ចាំ។

សម្រាប់ព័ត៌មានបន្ថែម៖ https://www.ftb.ca.gov/about-ftb/newsroom/golden-state-stimulus/gss-i.html

## Golden State Stimulus II (GSS II)

**លក្ខណ:សម្បត្តិ៖** បានដាក់លិខិតប្រកាសពន្ធឆ្នាំ 2020 និងមានចំណូលផ្ទៀងផ្ទាត់រួចចំនួន $75,000 ឬតិចជាងនេះ និងជាអ្នកប្រកាសពន្ធមានលេខ ITIN។

**សេចក្តីលម្អិត៖** GSS II ផ្តល់ប្រាក់មួយលើកចំនួន $500 ជូនបុគ្គលទាំងឡាយដែលបានទទួល GSS I ហើយមានកូនក្នុងបន្ទុក ចំនួន $600 សម្រាប់បុគ្គលទាំងឡាយ ដែលមិនបានទទួល GSS I ជាមួយនឹងប្រាក់ $500 បន្ថែម សម្រាប់គ្រួសារមានសមាជិកក្នុងបន្ទុក ហើយនិងចំនួន $500 ($1,000 សម្រាប់បុគ្គលមានអ្នកក្នុងបន្ទុក) សម្រាប់អ្នកប្រកាសពន្ធមានលេខ ITIN។

**សម្រាប់ព័ត៌មានបន្ថែម៖** https://www.ftb.ca.gov/about-ftb/newsroom/golden-state-stimulus/gss-ii.html